# គោលការណ៍ព្រមព្រៀង

ស្តីពី

កិច្ចសហប្រតិបត្តិការក្នុងការបង្ការ

និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជាពិសេសស្ត្រី

និងកុមារឆ្លងកាត់ព្រំដែន

កម្ពុជា-វៀតណាម

ភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧

# សមាសភាព គណៈប្រតិភូ នគរបាលជាតិកម្ពុជា

**<u>ប្រធានគណៈប្រតិភូ</u> :**

១. ឧត្តមសេនីយ៍ទោ **ម៉ិត គឹមហុង** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

**<u>សមាជិកគណៈប្រតិភូ</u> :**

២. វរៈសេនីយ៍ឯក **យឹម ថិរៈ** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

៣. វរៈសេនីយ៍ឯក **រាជ សុខុន** ស្នងការរងទទួលផែនបទល្មើសនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

៤. វរៈសេនីយ៍ទោ **សុខ រស្មី** នាយរងការិយាល័យរដ្ឋបាលសរុបនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

៥. វរៈសេនីយ៍ទោ **ម៉ឺុង គឹមឈួន** ស្នងការរងទទួលផែនបទល្មើសនៃស្នងការដ្ឋាននគរបាលខេត្តតាកែវ

៦. វរៈសេនីយ៍ទោ **ចាន់ សារឿន** ស្នងការរងទទួលផែនបទល្មើសនៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល

៧. វរៈសេនីយ៍ទោ **ស្រេង ជា** ស្នងការរងទទួលផែនបទល្មើសនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

៨. វរៈសេនីយ៍ទោ **ហែម សាធាន** ស្នងការរងទទួលផែនបទល្មើសនៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង

៩. វរៈសេនីយ៍ទោ **នួន សារី** ស្នងការរងទទួលផែនបទល្មើសនៃស្នងការដ្ឋាននគរបាលខេត្តកំពត

១០. វរៈសេនីយ៍ទោ **កៅ លឹមហេង** ស្នងការរងទទួលផែនបទល្មើសនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម

# សមាសភាព គណៈប្រតិភូ នគរបាលវៀតណាម

**ប្រធានគណៈប្រតិភូ :**

១. ឧត្តមសេនីយ៍ទោ ហ្វាង តឹងវៀត អនុប្រធាននាយកដ្ឋាននគរបាល ស៊ើបអង្កេតសណ្តាប់ធ្នាក់សង្គម ក្រសួងនគរបាល

**សមាជិកគណៈប្រតិភូ :**

២. វរៈសេនីយ៍ឯក ង្វៀង សុនត្វា អនុប្រធាននាយកដ្ឋានសេនាធិការ ក្រសួងនគរបាល

៣. វរៈសេនីយ៍ឯកបំរុង ដាំង សុនខាង អនុប្រធានការិយាល័យ Interpol

៤. វរៈសេនីយ៍ឯក ផាន គួកថាយ អនុប្រធាននាកដ្ឋាននគរបាលអន្តោប្រវេសន៏ ក្រសួងនគរបាល

៥. វរៈសេនីយ៍ឯកបំរុង ង្វៀងធ្រួង ធិញ អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងនគរបាល

៦. វរៈសេនីយ៍ឯកបំរុង ផាមទ៉ាន់ ហុង ប្រធានការិយាល័យការពារប្រឆាំងការជួញដូរស្ត្រី និងកុមារ-C14 ប្រធានការិយាល័យ

៧. វរៈសេនីយ៍ឯកបំរុង ឡេ ទ៉ាន់ជៀន ប្រធានការិយាល័យប្រចាំការ ១៣០/រដ្ឋាភិបាលក្រសួងនគរបាល

៨. វរៈសេនីយ៍ឯកបំរុង ង៉ូ វៀតហុង អនុប្រធានការិយាល័យសេនាធិការ នាយកដ្ឋានស៊ើបអង្កេតនគរបាល សណ្តាប់ធ្នាប់សង្គម ក្រសួងនគរបាល

៩. វរៈសេនីយ៍ឯកបំរុង ឡេ ទ៉ុកតៀង អនុប្រធានការិយាល័យស៊ើបអង្កេតសណ្តាប់ធ្នាប់សង្គម នគរបាល ក្រុងហូជីមិញ

១០. វរៈសេនីយ៍ទោ កៅ ទ៉ាន់ញឹន អនុប្រធានការិយាល័យស៊ើបអង្កេតសណ្តាប់ធ្នាប់សង្គម នគរបាល ខេត្តតៃនិញ

១១. វរៈសេនីយ៍ឯកបំរុង ង៉ូ មិញយុង អនុប្រធានការិយាល័យស៊ើបអង្កេតសណ្តាប់ធ្នាប់សង្គម នគរបាល ខេត្តគៀនយ៉ាង

១២.វរៈសេនីយ៍ឯកបំរុង ង្វៀង ថាន់ហាយ អនុប្រធានការិយាល័យស៊ើបអង្កេតសណ្តាប់ធ្នាប់សង្គម នគរបាល ខេត្តអានយ៉ាង

១៣.វរៈសេនីយ៍ឯកបំរុង ឡេ ទ៉ាន់មែសៅ អនុប្រធានការិយាល័យស៊ើបអង្កេតសណ្តាប់ធ្នាប់សង្គម នគរបាល ខេត្តដុងថាប់

១៤. វរៈសេនីយ៍ឯកបំរុង ង្វៀង ទ៉ុកថឹន អនុប្រធានការិយាល័យស៊ើបអង្កេតសណ្តាប់ធ្នាប់សង្គម នគរបាល ខេត្តប៊ិញភឿក

១៥. វរៈសេនីយ៍ឯកបំរុង ហ្វាង ទ៉ាន់ថាំង អនុប្រធានការិយាល័យស៊ើបអង្កេតសណ្តាប់ធ្នាប់សង្គម នគរបាល ខេត្តឡុងអាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌
នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស
និងការពារអនីតិជន
លេខ :..................

ភ្នំពេញ,ថ្ងៃទី.........ខែ..........ឆ្នាំ២០០៧

**គោរពជូន**

**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ**

ជាទីគោរពសូមជ្រាប ។

**តាមរយៈ** : **ឯកឧត្តមប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌**

**ឯកឧត្តម អគ្គស្នងការរងនគរបាលជាតិ ទទួលផែននគរបាលយុត្តិធម៌**

**កម្មវត្ថុ** : របាយការណ៍ស្តីពី កិច្ចប្រជុំរវាងកម្ពុជា និងវៀតណាម ក្នុងការប្រយុទ្ធប្រឆាំង និងការជួញដូរមនុស្ស ឆ្លងកាត់ព្រំដែន និងការចុះហត្ថលេខាលើគោលការណ៍ ព្រមព្រាង ស្តីពី កិច្ចសហប្រតិបត្តិការបង្ការ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ឆ្លងកាត់ព្រំដែន កម្ពុជា-វៀតណាម ។

**យោង** : -លិខិតលេខ ១១០៩ ល.ស ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ
-ចំណារឯកភាពចុះថ្ងៃទី១៧/១០/២០០៧ របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសគោរពនិងជំរាបជូនឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ មេត្តាជ្រាបថា : គណៈប្រតិភូនគរបាលជាតិកម្ពុជា ដឹកនាំដោយឧត្តមសេនីយ៍ទោ **ប៊ិត គីមហុង** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងសមាជិកប្រតិភូចំនួន ០៩នាក់ ក្នុងនោះមានសមាសភាព នាយនគរបាលរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ០២រូប ( អនុប្រធាននាយដ្ឋាន ០១រូប, អនុការិយាល័យរដ្ឋបាល ០១រូប ) ស្នងការរងតាមបណ្តាខេត្ត-ក្រុងចំនួន ០៧រូប មាន (**តាកែវ, កណ្តាល, ព្រៃវែង, ស្វាយរៀង, កំពត, កំពង់ចាម និងភ្នំពេញ**) ។

នៅថ្ងៃទី ២៣/១០/២០០៧ ក្នុងខេត្តតៃនិញប្រទេសវៀតណាម បានបើកកិច្ចប្រជុំមួយដែលបានរៀបចំឡើងនៅក្នុងសណ្ឋាគារ **ហ័រ ប៊ិញ** អំពីប្រធានបទស្តីពី ការប្រយុទ្ធប្រឆាំង និងអំពើជួញដូរមនុស្ស ជាពិសេសលើ ស្ត្រី និងកុមារ ឆ្លងកាត់ព្រំដែនកម្ពុជា និងវៀតណាម ឧបត្ថម្ភដោយអង្គការ Unicef ។

គណៈប្រតិភូនៃភាគីនគរបាលវៀតណាម ដឹកនាំដោយលោកវរៈសេនីយ៍ឯក **ហ្វាង តឺទៀត** អនុប្រធាននាយកដ្ឋាននគរបាលស៊ើបអង្កេតសណ្តាប់ធ្នាប់សង្គម សមាជិកប្រតិភូមានចំនួន ១៤នាក់ ក្នុងនោះមានសមាសភាពថ្នាក់ដឹកនាំមកពី ក្រសួងនគរបាលវៀតណាមចំនួន ០៧រូប និង ថ្នាក់ដឹកនាំនគរបាលមកពីបណ្តាខេត្តចំនួន០៧រូប មាន (**តៃនិញ, គៀងយ៉ាង, អានយ៉ាង, ដុងថាប់, ប៊ិញភឿក, ឡុងអាន និងហូជីមិញ**) ។

សមាសភាពចូលរួមប្រជុំជាមួយមាន : តំណាងនាយកដ្ឋានស៊ើបការអគ្គបញ្ជាការកងទ័ពព្រំដែន

តំណាងក្រសួងពលកម្ម យុទ្ធជនពិការ និងសង្គមកិច្ច តំណាងគណៈកម្មការឃោសនានៃសមាគមន៍សម្ព័ន្ធនារី VN តំណាងកងទ័ពព្រំដែនខេត្ត( **តៃនិញ, ប៊ិញភឿក, គៀងយ៉ាង, អានយ៉ាង, ដុងថាប និងឡុងអាន** ) តំណាងអង្គការ (UNICEF, UNODC, ARTIP, IOM ) ។

កិច្ចប្រជុំបានផ្តើមតាមកម្មវិធីគ្រោងទុកក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧត្តមសេនីយ៍ទោ **ផាន ណាមតៅ** អគ្គនាយករងនគរបាលវៀតណាម អង្គប្រជុំបានដំណើរការរយៈពេល ០២ថ្ងៃ (ចាប់ពីថ្ងៃទី ២៣-២៤/១០/២០០៧)ក្រោមបរិយាកាសស្និតស្នាល និងសាមគ្គីភាព មិត្តភាពរវាងភាគីទាំង០២ កម្ពុជានិង វៀតណាម ក្នុងនោះភាគីទាំង០២បានពិភាក្សាលំអិតលើខ្លឹមសារគោលការណ៍ ពង្រាងចំនួន១០ចំណុច ក្នុងកិច្ចសហប្រតិបត្តិការរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងបទល្មើសជួញដូរមនុស្ស ឆ្លងកាត់ព្រំដែន ជាពិសេសទៅលើស្ត្រី និងកុមារ ដើម្បីយកទៅកេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទ ព្រមទាំងការសង្គ្រោះជនរងគ្រោះដោយសារការជួញដូរ មនុស្ស និងការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ។

ក្រោយពីការពិនិត្យ និងកែសម្រួលលើខ្លឹមសារ ពង្រាងគោលការណ៍នៃកិច្ចសហប្រតិបត្តិការរវាង ប្រទេសទាំង០២មក នៅព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧ យើងបានឯកភាពគ្នា ចុះហត្ថលេខាលើ គោលការណ៍ ព្រមព្រាង កិច្ចសហប្រតិបត្តិការ បង្ការ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ ឆ្លងកាត់ព្រំដែនកម្ពុជា និងវៀតណាម ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើសូម ឯកឧត្តមនាយ ឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិ មេត្តាជ្រាបជាសេចក្តីរាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូមជូនភ្ជាប់មកជាមួយនូវឯកសារចុះហត្ថលេខាលើ គោលការណ៍ព្រមព្រាង របស់ភាគីទាំងពីរ ។

សូមឯកឧត្តម នាយឧត្តមសេនីយ៍ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

**ប្រធាននាយកដ្ឋាន**

# គោលការណ៍ព្រមព្រៀង
# ស្តីពី
# កិច្ចសហប្រតិបត្តិការក្នុងការបង្ការ និងបង្ក្រាប បទល្មើសជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារឆ្លងកាត់ព្រំដែន កម្ពុជា_វៀតណាម

ចាប់ពីថ្ងៃទី ២៣ ដល់ ២៤ ខែតុលា ឆ្នាំ២០០៧ នៅខេត្ត **តៃនិញ** ប្រទេសវៀតណាម

គណៈប្រតិភូវៀតណាមដឹកនាំដោយ លោក**វរសេនីយ៍ឯក ហ៊ាំង តឹនទៀត អនុប្រធាននាយកដ្ឋាននគរបាលស៊ើបអង្កេតបទល្មើសផ្នែកសណ្តាប់ធ្នាប់សង្គមនៃក្រសួងនគរបាលវៀតណាម** និងគណៈប្រតិភូនគរបាលជាតិកម្ពុជាដឹកនាំដោយលោក**ឧត្តមសេនីយ៍ទោ ប៊ិត គឹមហុង ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃកម្ពុជា** (ដែលចាប់ពីពេលនេះ ទៅហៅកាត់ថា "**ពីរភាគី**" បានរៀបចំកិច្ចប្រជុំស្តីពី កិច្ចសហប្រតិបត្តិការបង្ការ និងបង្ក្រាបបទល្មើសជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារឆ្លងកាត់ព្រំដែន វៀតណាម កម្ពុជា។

គណៈប្រតិភូវៀតណាមរួមមានបណ្តាតំណាងថ្នាក់ដឹកនាំនៃនាយកដ្ឋាន ស៊ើបអង្កេតបទល្មើសផ្នែកសណ្តាប់ធ្នាប់សង្គម និងបណ្តាអង្គភាពពាក់ពន្ធ័ មកពី ក្រសួងនគរបាលវៀតណាម ការិយាល័យស៊ើបអង្កេតបទល្មើស ផ្នែកសណ្តាប់ធ្នាប់សង្គម នៃនគរបាលបណ្តាខេត្ត**តៃនិញ-គៀងយ៉ាង-អាងយ៉ាង-ដុងថាប-ឡុងអាន និងខេត្តប៊ិញហ្វឿក**ព្រមទាំងទីក្រុង**ហូជីមិញ** បណ្តាអង្គភាព និងស្ថាប័ចំណុះបណ្តាក្រសួង មន្ទីរ នាយកដ្ឋានស៊ើបការណ៍ នៃអគ្គបញ្ជាការដ្ឋានកងទ័ពការពារព្រំដែន នាយកដ្ឋានប្រឆាំងអំពើអបាយមុខសង្គម នៃក្រសួងការងារយុទ្ធជនពិការ និងសង្គមកិច្ច គណៈឃោសនា អប់រំ នៃមជ្ឈឹមសមាគមន៍នារីវៀតណាម ។

គណៈប្រតិភូកម្ពុជារួមមាន ថ្នាក់ដឹកនាំ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ ថ្នាក់ដឹកនាំមកពីបណ្តាស្នងការដ្ឋាននគរបាលខេត្ត-ក្រុង មាន : **ខេត្តតាកែវ-កណ្តាល-ព្រៃវែង-ស្វាយរៀង-កំពត-កំពង់ចាម និងរាជធានីភ្នំពេញ** ។ (***មានភ្ជាប់បញ្ជីឈ្មោះមកជាមួយ***)

កិច្ចប្រជុំបានដំណើរការក្នុងបរិយាកាសមិត្តភាព និងការយោគយល់ ជឿជាក់លើគ្នាទៅវិញទៅមក និងមានចរឹតស្ថាបនា ។

ភាគីទាំងពីរបានធ្វើការផ្លាស់ប្តូរ និងវាយតំលៃខ្ពស់ការអនុវត្តន៍ កិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីរវាង កម្ពុជា វៀតណាម ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារនិងការគាំទ្រជនរងគ្រោះដោយអំពើជួញដូរ និងកិច្ចសហប្រតិបត្តិការ តស៊ូប្រឆាំងបទល្មើសជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារឆ្លងដែន ក្នុងរយៈកាលកន្លងមក ។

កងកំលាំងនគរបាលនៃប្រទេសទាំងពីរបានដាក់ចេញនូវវិធានការនិងរូបភាពសហការជាច្រើនមានប្រសិទ្ធភាពក្នុងការស្វែងរកឃើញ ស៊ើបអង្កេតបំផ្លាញខ្សែរយៈចាត់តាំងជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារឆ្លងដែន ចាប់ឃាត់ខ្លួន មុខសញ្ញាល្មើស រំដោះ និងធានាសុវត្ថិភាពក្នុងការបញ្ជូនត្រឡប់ ជនរងគ្រោះដោយសារការជួញដូរ រួមចំណែករក្សាសណ្តាប់ធ្នាប់សន្តិសុខសង្គមនៅតំបន់ព្រំដែន។

ភាគីទាំងពីរ ត្រូវបន្តការ ពង្រឹង និងបង្កើន ទំនាក់ទំនង កិច្ចសហប្រតិបត្តិការមិត្តភាព និងដោះស្រាយដោយប្រសិទ្ធភាព នូវរាល់បញ្ហាដែលពាក់ព័ន្ធដល់ ប្រទេសទាំងពីរក្នុងការ បង្ការប្រឆាំងនឹងបទល្មើសជួញដូរមនុស្ស

ស្ត្រី និងកុមារនិងជួយដល់ជនរងគ្រោះដោយអំពើជួញដូរ ។ ឈរលើស្មារតីនោះ ភាគីទាំងពីរបានព្រមព្រៀងគ្នាធ្វើកិច្ចសហប្រតិបត្តិការដូចតទៅ :

១-ភាគីទាំងពីរ ចាត់ទុកថា: កិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ និងការគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរ គឺជាមូលដ្ឋានដើម្បីដំណើរការសកម្មភាពកិច្ចសហប្រតិបត្តិការជាក់ស្តែង រវាងភាគីទាំងពីរក្នុងកិច្ចប្រតិបត្តិការបង្ការបង្ក្រាបបទល្មើសជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារឆ្លង កាត់ព្រំដែនកម្ពុជា-វៀតណាម ។

២-ភាគីទាំងពីរត្រូវបង្កើនការផ្សព្វផ្សាយអប់រំសំដៅលើកកំពស់ការយល់ដឹង នៅក្នុងចំណោមប្រជាពលរដ្ឋស្តីពីការគោរពប្រតិបត្តិ គោលនយោបាយ ច្បាប់ រក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងស្ថេរភាព នៅតាមតំបន់ព្រំដែន មិនធ្វើជាមេខ្យល់ ជ្រើសរើស ដឹកជញ្ជូនមនុស្សខុសច្បាប់ឆ្លងកាត់ព្រំដែនឬជួញដូរមនុស្សដើម្បីកេងប្រវ័ញ្ចពលកម្ម ឬផ្លូវភេទជាពិសេសលើស្ត្រី និងកុមារហើយរួមសហការជាមួយបណ្តាស្ថាប័នមានសមត្ថកិច្ចដើម្បីស្វែងរក ទប់ស្កាត់បទល្មើស ជួញដូរមនុស្សជាពិសេសលើស្ត្រី និងកុមារ ។

៣-ធ្វើការផ្លាស់ប្តូរទាន់ពេលវេលានូវបណ្តាពត៌មានឯកសារស្តីពីបទល្មើសជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារដែលមានការពាក់ពន្ធ័ដល់ប្រទេសទាំងពីរក្នុងនោះរួមទាំងពត៌មានស្តីពីរឿងហេតុជនរងគ្រោះ មុខសញ្ញាល្មើសច្បាប់ វិធីសាស្ត្រ ល្បិចកលធ្វើសកម្មភាព បណ្តាភូមិសាស្ត្រសំខាន់ៗនិងផ្តើមសំណូមពរដើម្បីសហការគ្នា។

ភាគីទទួលបាន សំណូមពរចាំបាច់ត្រូវរក្សាពត៌មាន ឱ្យបានសំងាត់ រួសរាន់ចាត់តាំងការស៊ើបបញ្ជាក់រួមសហការ និងអនុវត្តបណ្តាវិធានាការ បង្ការ ទប់ស្កាត់ ស៊ើបអង្កេត ចាប់ខ្លួន ជនប្រព្រឹត្តបទល្មើស ឬរំដោះជនរងគ្រោះ និងជូនដំណឹងឱ្យទៅភាគីដែលបានសំណូមពរបានជ្រាបក្នុងរយៈពេលដ៏ឆាប់បំផុត ។

៤-ភាគីទាំងពីរត្រូវបង្កើនការសហការការស៊ើបបញ្ជាក់រៀបចំការប្រគល់ ជនរងគ្រោះដោយអំពើជួញដូរដោយធានាថា ជនរងគ្រោះដោយសារការជួញដូរមនុស្ស បានទទួលការប្រព្រឹត្តដោយមនុស្សធម៌ និងជួយឧបត្ថម្ភការធ្វើមាតុភូមិនិវត្តន៍បានយ៉ាងឆាប់រហ័សទាន់ពេលវេលា ។

៥-ភាគីទាំងពីរ ត្រូវជូនដំណឹងអោយគ្នាទៅវិញទៅមក ពីបទបញ្ញត្តិច្បាប់ ដែលពាក់ព័ន្ធដល់កិច្ចប្រតិបត្តិ-ការបង្ការបង្ក្រាបបទល្មើសជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ បណ្តាបែបបទនីតិវិធី និងពត៌មានផ្សេងៗទៀត ......សំដៅធានាកិច្ចសហការរវាង កងកំលាំងមានសមត្ថកិច្ច នៃភាគីទាំងពីរ ក្នុងកិច្ចប្រតិបត្តិការបង្ការ បង្ក្រាបបទល្មើសជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារសមស្របទៅតាមច្បាប់នៃប្រទេសនីមួយៗ និងច្បាប់អន្តរជាតិ ។

៦.ភាគីទាំងពីរដំណើរការអង្កេតពីសភាពការណ៍ជួញដូរមនុស្ស ឆ្លងកាត់ព្រំដែន កម្ពុជា-វៀតណាម សំដៅវាយតំលៃស្ថានភាពពិត ដើម្បីស្នើសុំគោលការណ៍ ថ្នាក់ដឹកនាំជាន់ខ្ពស់ និងស្ថាប័នមានសមត្ថកិច្ចមានវិធានការសហការដោះស្រាយ ។

- ភាគីវៀតណាមចាត់តាំងការអង្កេតពីសភាពការណ៍ ស្ត្រី និងកុមារដែលត្រូវបានគេជួញដូរ និងសង្ស័យថាត្រូវបានគេជួញដូរ និងត្រូវផ្តល់ដំណឹងជូននគរបាលកម្ពុជាបានជ្រាបពីមុខសញ្ញា ខ្សែរយៈចាត់តាំងជួញដូរមនុស្សពីវៀតណាមដែលកំពុងលាក់ខ្លួននៅកម្ពុជា និងជនរងគ្រោះដោយអំពើជួញដូរដែលមានអាស័យដ្ឋានច្បាស់លាស់នៅកម្ពុជា ដែលចាំបាច់ត្រូវរំដោះ ។
- ភាគីកម្ពុជាចាត់តាំងការអង្កេតពីសភាពការណ៍ស្ត្រី និងកុមារវៀតណាម ដែលត្រូវបានគេជួញដូរទៅ

កម្ពុជា វាយតំលៃពីជនរងគ្រោះនៅតាម ខេត្ត-ក្រុងនីមួយៗធ្វើការកំណត់ ភូមិសាស្ត្រសំខាន់ៗ បណ្តាមុខសញ្ញា បក្ខពួក ក្រុមប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសដែលបានចូលរួមក្នុងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារវៀតណាម និងផ្តល់ដំណឹងជូន នគរបាលវៀតណាម ដើម្បីរួមសហការ បង្ការ បង្ក្រាប ។

៧-ភាគីទាំងពីរ រួមសហការបើកយុទ្ធនាការក្នុងការបង្ការ បង្ក្រាបបទល្មើស ជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារឆ្លងកាត់ព្រំដែន វៀតណាម-កម្ពុជា សំដៅបង្កើនការ បង្ក្រាប និងចាប់ខ្លួន មុខសញ្ញាប្រព្រឹត្តបទល្មើស រំដោះ និងប្រគល់ជនរងគ្រោះដែលត្រូវគេជួញដូរ និងលើកកំពស់ប្រសិទ្ធភាព វិនិច្ឆ័យជនល្មើសជួញដូរមនុស្ស របស់ប្រទេសនីមួយៗ។រយៈពេលនៃការអនុវត្តវគ្គយុទ្ធនាការគឺអាស្រ័យលើភាគីទាំងពីរឯកភាពគ្នា ។ភាគីនីមួយៗ ត្រូវមានផែនការជាក់ស្តែងដើម្បីអនុវត្តឱ្យស្របទៅ នឹងសភាពការណ៍ជាក់ស្តែង នៃប្រទេសនីមួយៗហើយផ្តល់ដំណឹងឱ្យគ្នាទៅវិញទៅមក ពីលទ្ធផលនៃការអនុវត្ត ។

៨-បង្កើតបណ្តាញផ្លាស់ប្តូរពត៌មាន រវាងកងកំលាំងនគរបាលនៃប្រទេសទាំងពីរ សំដៅក្តាប់ជាប់សភាពការណ៍ និងរួមសហការដោះស្រាយបានឆាប់រហ័សទាន់ពេល ចំពោះរឿងហេតុមុខសញ្ញា និងជនរងគ្រោះដោយអំពើជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារដែលមានការពាក់ពន្ធ័ដល់ប្រទេសទាំងពីរ ។ក្រៅពីបណ្តាញពត៌មានតាមរយៈការិយាល័យ INTERPOL និងស្ថាប័នសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសនីមួយៗ រក្សាការផ្លាស់ប្តូរពត៌មានជួបប្រជុំតាមកាលកំណត់រវាងនគរបាលមូលដ្ឋានថ្នាក់ខេត្ត ថ្នាក់ស្រុក ដែលមានព្រំប្រទល់ជាប់គ្នា។ អនុវត្តការផ្លាស់ប្តូរពត៌មាន ដោយផ្ទាល់ រវាងនាយកដ្ឋាននគរបាលស៊ើបអង្កេតបទល្មើស សណ្តាប់ធ្នាប់សង្គម នៃក្រសួងនគរបាលបាលវៀតណាមជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃកម្ពុជា តាមរយៈទូរសព្ទ័ ទូរសារ និងបណ្តារូបភាពទំនាក់ទំនងផ្សេងៗទៀត។

៩-ភាគីទាំងពីរព្រមព្រៀងបន្តរៀបចំកិច្ចប្រជុំតាមកាលកំណត់ដូចបានឯកភាពគ្នាពីមុនមក និងរៀបចំបើកវគ្គបណ្តុះបណ្តាលរួមគ្នា ដោយមានការឧបត្ថម្ភគាំទ្រពីបណ្តាអង្គការអន្តរជាតិជាដៃគូរ ។ពេលវេលានិងទីកន្លែងជាក់ស្តែងគឺអាស្រ័យដោយភាគីទាំងពីរឯកភាពគ្នា ។

១០-ភាគីទាំងពីរ នឹងធ្វើការផ្សព្វផ្សាយ និងសហការជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់ប្រទេសខ្លួនដើម្បីដំណើរការអនុវត្តឱ្យមានប្រសិទ្ធិភាព នូវខ្លឹមសារដែលបានចែងក្នុងគោលការណ៍ព្រមព្រៀងនេះ ។

គោលការណ៍ព្រមព្រៀង នេះត្រូវបានចុះហត្ថលេខានៅខេត្តតៃនិញប្រទេសវៀតណាមនៅថ្ងៃទី២៤ខែតុលាឆ្នាំ២០០៧ដែលមាន ពីរច្បាប់ជាភាសាខ្មែរ និងភាសាវៀតណាមហើយមានសុពលភាពដូចគ្នា។

| | |
|---|---|
| ប្រធានគណៈប្រតិភូកម្ពុជា | ប្រធានគណៈប្រតិភូវៀតណាម |
| ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស | អនុប្រធាននាយកដ្ឋាន នគរបាលស៊ើប |
| និងការពារអនីតិជន | អង្កេតបទល្មើសសណ្តាប់ធ្នាប់សង្គម |
| ឧត្តមសេនីយ៍ទោ ប៊ិត គីមហុង | វរសេនីយ៍ឯក ហ្វាង គីនទៀន |